រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤១០៧៤ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្តីពី
# ក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងលិខិតលេខ១០២៨ សជណ.មយ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងដើម្បីលើកកម្ពស់ការគោរព និងពង្រឹងគោលការណ៍នីត្យានុកូលភាពនៃលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីសម្រេចនានារបស់រដ្ឋបាលរាជធានី ខេត្ត និងជានាការពារផលប្រយោជន៍ស្របច្បាប់របស់រដ្ឋបាលរាជធានី ខេត្ត នៅពេលមានបណ្តឹងទាមទារ បណ្តឹងតវ៉ា ឬបណ្តឹងផ្សេងទៀត ដោយកំណត់អំពីការរៀបចំឱ្យមានក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ ២.-**

ក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្តនីមួយៗ មានចំនួនចាប់ពី ០២ (ពីរ)រូប ទៅដល់ ០៤ (បួន)រូប អាស្រ័យទៅតាមកត្តាប្រជាសាស្ត្រ ភូមិសាស្ត្រ ទំហំការងារ និងតម្រូវការសេវាផ្លូវច្បាប់ នៃរដ្ឋបាលរាជធានី ខេត្តនីមួយៗ ដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។ ក្រសួងមហាផ្ទៃអាចធ្វើការកែសម្រួលចំនួនក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត តាមការចាំបាច់។

ការទទួលស្គាល់មេធាវីឱ្យបំពេញការងារតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ ៣.-**

ការជ្រើសតាំងក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមលក្ខខណ្ឌគតិយុត្តដូចខាងក្រោម៖

- មានឆន្ទៈចង់បំពេញការងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិដោយការស្ម័គ្រចិត្ត

- ជាមេធាវីពេញសិទ្ធិ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងមានបទពិសោធន៍ប្រកបវិជ្ជាជីវៈមេធាវីយ៉ាងតិច ០២ (ពីរ) ឆ្នាំ
- មានជំនាញ និងបទពិសោធន៍វិជ្ជាជីវៈមេធាវីផ្នែករដ្ឋបាលសាធារណៈ នីតិរដ្ឋប្បវេណី នីតិព្រហ្មទណ្ឌ នីតិពាណិជ្ជកម្ម នីតិវិនិយោគ និងច្បាប់ផ្សេងៗទៀត។ ក្នុងការចាត់តាំងសមាជិកក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវជ្រើសឱ្យមានជំនាញផ្សេងៗគ្នា
- មានទីលំនៅ ឬការិយាល័យ ឬស្នាក់ការមេធាវីនៅក្នុងរាជធានី ខេត្ត ដែលសាមីខ្លួនត្រូវទៅបំពេញការងារ។ ករណីមិនអាចរកបានមេធាវីស្ម័គ្រចិត្តដែលមានទីលំនៅ ឬការិយាល័យ ឬស្នាក់ការមេធាវីក្នុងខេត្តសាមី រដ្ឋបាលខេត្តអាចធ្វើការចាត់តាំងមេធាវីដែលមានទីលំនៅ ឬការិយាល័យ ឬស្នាក់ការមេធាវីក្នុងរាជធានី ខេត្តដែលនៅជាប់ព្រំប្រទល់គ្នា ឬពីរាជធានី ខេត្តផ្សេង
- ត្រូវផ្តល់អាទិភាពដល់មេធាវីជាស្ត្រី និងមេធាវីជាជនពិការដែលមានសមត្ថភាព
- មិនធ្លាប់ទទួលរងទណ្ឌកម្មវិន័យ និង/ឬការផ្តន្ទាទោសទាំងឡាយណាដែលនាំដល់ការហាមឃាត់ ឬដកហូត ឬព្យួរការប្រកបវិជ្ជាជីវៈមេធាវី
- មិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ដែលខ្លួនត្រូវស្នើជាអ្នកតំណាងដោយអាណត្តិ និង/ឬជួយការពារផលប្រយោជន៍។

**ប្រការ ៤.-**

ក្រសួងមហាផ្ទៃ ដោយមានអគ្គនាយកដ្ឋានរដ្ឋបាលជាសេនាធិការ ត្រូវរៀបចំបញ្ជីបេក្ខភាពក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត ដោយត្រូវពិគ្រោះយោបល់ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត មុននឹងដាក់ចេញប្រកាសទទួលស្គាល់មេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត។

ក្នុងករណីចាំបាច់ដែលតម្រូវដោយក្រមសីលធម៌មេធាវី និង/ឬស្ថានភាពចាំបាច់ផ្សេងទៀត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាចស្នើសុំមកក្រសួងមហាផ្ទៃធ្វើការពិនិត្យលទ្ធភាពផ្លាស់ប្តូរ និង/ឬកែសម្រួលសមាសភាពក្រុមមេធាវីប្រចាំរាជធានី ខេត្តរបស់ខ្លួនបាន តាមការចាំបាច់។

**ប្រការ ៥.-**

មេធាវីដែលត្រូវចាត់តាំងឱ្យទៅបំពេញការងារនៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ផ្តល់យោបល់ផ្លូវច្បាប់ចំពោះការចេញដីកា ឬសេចក្តីសម្រេច និងលិខិតបទដ្ឋាននានារបស់រដ្ឋបាលរាជធានី ខេត្ត ដោយត្រូវសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធនានារបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងករណីមានសំណើពីរដ្ឋបាលរាជធានី ខេត្ត
- ពិនិត្យ និងផ្តល់យោបល់ផ្លូវច្បាប់ចំពោះការចេញដីកា ឬសេចក្តីសម្រេចនានា របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលស្ថិតក្រោមសមត្ថកិច្ចដែនដីរបស់រាជធានី ខេត្ត ដែលមេធាវីត្រូវបានចាត់តាំងឱ្យទៅបំពេញការងារ ក្នុងករណីមានសំណើពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ពិនិត្យ និងផ្តល់យោបល់ផ្លូវច្បាប់ចំពោះកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នានានា ដែលរដ្ឋបាលរាជធានី ខេត្ត នឹងត្រូវចុះ ឬបានចុះហត្ថលេខាជាមួយភាគីណាមួយ

- ពិនិត្យផ្តល់យោបល់ផ្លូវច្បាប់ចំពោះកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នា ដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នឹងត្រូវចុះ ឬបានចុះហត្ថលេខាជាមួយភាគីណាមួយ ក្នុងករណីមានសំណើពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- បំពេញតួនាទីជាមេធាវីតំណាង ឬការពារក្តីឱ្យរដ្ឋបាលរាជធានី ខេត្ត ដែលខ្លួនបំពេញការងារ ក្នុងករណីមានបណ្តឹងតវ៉ា បណ្តឹងទាមទារពីភាគីណាមួយ តាមការប្រគល់សិទ្ធិពីរដ្ឋបាលរាជធានី ខេត្ត
- សហការរៀបចំពាក្យបណ្តឹងឱ្យរដ្ឋបាលរាជធានី ខេត្ត និងបំពេញតួនាទីជាមេធាវីតំណាង និងការពារផលប្រយោជន៍ឱ្យរដ្ឋបាលរាជធានី ខេត្ត
- ធ្វើជាមេធាវីតំណាង ឬការពារឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ចំពោះមុខតុលាការ ឬស្ថាប័នមានសមត្ថកិច្ច ក្នុងករណីមានការប្តឹងផ្តល់ជាមួយភាគីណាមួយ តាមការស្នើសុំពីរដ្ឋបាលរាជធានី ខេត្តដែលខ្លួនបំពេញការងារ
- អាចចូលរួម និងផ្តល់យោបល់ផ្លូវច្បាប់ដល់អង្គប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត ករណីមានការអញ្ជើញឱ្យចូលរួមប្រជុំ និងស្នើសុំយោបល់ពីអង្គប្រជុំ តែមិនមានសិទ្ធិសម្រេច និងអនុម័តក្នុងអង្គប្រជុំ
- ផ្តល់ការប្រឹក្សាយោបល់ផ្លូវច្បាប់ និងធ្វើជាមេធាវីការពារ ឬតំណាងឱ្យគណៈអភិបាល សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលទទួលរងបណ្តឹងដោយសារតែការបំពេញការងាររបស់ខ្លួន
- សហការចូលរួមធ្វើការបណ្តុះបណ្តាល ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដល់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការចាត់តាំងពីអភិបាលរាជធានី ខេត្ត
- ផ្តល់ការប្រឹក្សាយោបល់ផ្លូវច្បាប់ដល់រដ្ឋបាលរាជធានី ខេត្ត ដើម្បីឱ្យដំណើរការសម្របសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានត្រឹមត្រូវតាមផ្លូវច្បាប់ និងលិខិតបទដ្ឋានជាធរមាន
- ទទួលអនុវត្ត និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់របស់អភិបាលរាជធានី ខេត្ត។

**ប្រការ ៦.-**

មេធាវីដែលត្រូវបានចាត់តាំងឱ្យទៅបំពេញការងារនៅតាមរដ្ឋបាលរាជធានី ខេត្ត ត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួន ស្របតាមសំណូមពរ ឬការប្រគល់ជូនរបស់គណៈអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ដោយមានលិខិតអញ្ជើញ ឬលិខិតប្រគល់សិទ្ធិ ឬលិខិតតំណាងដោយអាណត្តិ ដើម្បីបំពេញការងារស្របតាមវិធានសីលធម៌វិជ្ជាជីវៈមេធាវី ច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

ការផ្តល់យោបល់ផ្លូវច្បាប់ ការផ្តល់តំណាង ឬការការពារក្តីណាមួយ ត្រូវធ្វើសម្រាប់ប្រយោជន៍ស្របច្បាប់របស់រដ្ឋបាលរាជធានី ខេត្ត ប្រយោជន៍សាធារណៈរបស់រដ្ឋបាលរាជធានី ខេត្តតែប៉ុណ្ណោះ។

ក្នុងករណីមានសំណើសុំជំនួយផ្លូវច្បាប់ណាមួយពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្តណាមួយ គណៈអភិបាលរាជធានី ខេត្តសាមីត្រូវពិនិត្យលើលទ្ធភាពក្នុងការចាត់តាំងមេធាវីឱ្យទៅជួយផ្តល់សេវាផ្លូវច្បាប់តាមការស្នើសុំ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងប្រកាសនេះ ក្រុមមេធាវីរដ្ឋបាលរាជធានី ខេត្ត អាចប្រើប្រាស់ត្រារបស់ខ្លួន ស្របតាមលក្ខខណ្ឌដែលកំណត់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៧.-**

ក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត ត្រូវបានចាត់តាំងឱ្យទៅបំពេញការងារនៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗ សម្រាប់រយៈពេល ៤ (បួន)ឆ្នាំ។

មេធាវីដែលចប់អាណត្តិការងារអាចត្រូវបានចាត់តាំងបន្តទៀតបាន ផ្អែកលើលទ្ធផលនៃការវាយតម្លៃលើការបំពេញការងាររបស់មេធាវីម្នាក់ៗ។

**ប្រការ ៨.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំប្រាក់ឧបត្ថម្ភប្រចាំខែដល់ក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត ដោយដាក់បញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួនដូចមាននៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ។

រដ្ឋបាលរាជធានី ខេត្ត ត្រូវគ្រោងថវិកាសម្រាប់សោហ៊ុយចំណាយផ្សេងៗក្នុងការបំពេញការងាររបស់មេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្តនៅក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ក្នុងករណីដែលក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត ផ្តល់សេវាជាប្រយោជន៍ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រដ្ឋបាលសាមីទាំងនោះ ត្រូវផ្តល់ប្រាក់បេសកកម្ម សោហ៊ុយធ្វើដំណើរ និងអត្ថប្រយោជន៍ផ្សេងទៀត ស្របតាមគោលការណ៍ដែលកំណត់ដោយរាជរដ្ឋាភិបាល ជូនដល់ក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ ៩.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវដាក់បញ្ចូលរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារសម្រេចបានរបស់ក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្តសាមី ទៅក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំរបស់ខ្លួនមកក្រសួងមហាផ្ទៃ។

**ប្រការ ១០.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារ និងហិរញ្ញវត្ថុ អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ ២១៧ ដ.ប្រក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១
## ស្តីពីក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត

| ល.រ | រាជធានី ខេត្ត | ចំនួនមេធាវី |
|---|---|---|
| ១ | រាជធានីភ្នំពេញ | ០៤ រូប |
| ២ | ខេត្តបាត់ដំបង | ០៤ រូប |
| ៣ | ខេត្តកណ្តាល | ០៤ រូប |
| ៤ | ខេត្តព្រៃវែង | ០៤ រូប |
| ៥ | ខេត្តកំពង់ចាម | ០៤ រូប |
| ៦ | ខេត្តកំពង់ធំ | ០៤ រូប |
| ៧ | ខេត្តសៀមរាប | ០៤ រូប |
| ៨ | ខេត្តតាកែវ | ០៣ រូប |
| ៩ | ខេត្តត្បូងឃ្មុំ | ០៣ រូប |
| ១០ | ខេត្តកំពង់ស្ពឺ | ០៣ រូប |
| ១១ | ខេត្តបន្ទាយមានជ័យ | ០៣ រូប |
| ១២ | ខេត្តកំពត | ០៣ រូប |
| ១៣ | ខេត្តស្វាយរៀង | ០៣ រូប |
| ១៤ | ខេត្តកំពង់ឆ្នាំង | ០៣ រូប |
| ១៥ | ខេត្តព្រះសីហនុ | ០៣ រូប |
| ១៦ | ខេត្តកោះកុង | ០៣ រូប |
| ១៧ | ខេត្តមណ្ឌលគិរី | ០៣ រូប |
| ១៨ | ខេត្តពោធិ៍សាត់ | ០៣ រូប |
| ១៩ | ខេត្តក្រចេះ | ០២ រូប |
| ២០ | ខេត្តប៉ៃលិន | ០២ រូប |
| ២១ | ខេត្តព្រះវិហារ | ០២ រូប |
| ២២ | ខេត្តរតនគិរី | ០២ រូប |
| ២៣ | ខេត្តស្ទឹងត្រែង | ០២ រូប |
| ២៤ | ខេត្តកែប | ០២ រូប |
| ២៥ | ខេត្តឧត្តរមានជ័យ | ០២ រូប |